ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពុទ្ធមណ្ឌលវិបស្សនាធុរៈ
នៃព្រះរាជាណាចក្រកម្ពុជា

# ធម្មបទគាថា ពាលវគ្គ ទី ៥

## បិដកលេខ ៥២ ទំព័រ ៣៤-៣៧

(១៥) ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ
ទីឃោ ពាលានំ សំសារោ សទ្ធម្មំ អវិជានតំ ។

រាត្រីវែងចំពោះតែអ្នកភ្ញាក់រឭក (អ្នកដែលមិនលក់) យោជន៍វែងចំពោះតែអ្នកនឿយហត់សង្សារវដ្តវែងចំ ពោះតែបុគ្គលពាលមិនដឹងច្បាស់នូវព្រះ-សទ្ធម្ម ។

ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ
ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា ។

បុគ្គលកាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯងឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថាសហា យតាគុណមិនមានក្នុងបុគ្គលពាលឡើយ ។

បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ
អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។

ជនពាលតែងព្រួយលំបាកដោយសេចក្តីសំគាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិតសូម្បីខ្លួនរបស់ខ្លួនក៏មិនមានចំណង់បើកូនទាំងឡាយនឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថាមានអំពីណាបាន ។

យោ ពាលោ មញ្ញតិ ពាល្យំ បណ្ឌិតោ វាបិ តេន សោ
ពាលោ ច បណ្ឌិតមានី ស វេ ពាលោតិ វុច្ចតិ ។

អ្នកណាជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថាជាពាល អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួនថាជាពាលនោះ ម្យ៉ាងទៀត

អ្នកណាជាមនុស្សពាល មានសេចក្តីប្រកាន់ថាខ្លួនជាបណ្ឌិត អ្នកនោះឈ្មោះថាជាមនុស្សពាល ដោយពិត។

យាវជីវម្បិ ចេ ពាលោ　　បណ្ឌិតំ បយិរុបាសតិ
ន សោ ធម្មំ វិជានាតិ　　ទព្វី សូបរសំ យថា ។

មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិតក៏ឥតមានដឹងរសធម៌អ្វីឲ្យច្បាស់លាស់ឡើយ ដូចវែកដែលមិនដឹងរសសម្ល ។

មុហុត្តមបិ ចេ វិញ្ញូ　　បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ　　ជិវ្ហា សូបរសំ យថា ។

វិញ្ញូជនបើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់រសធម៌ ដោយឆាប់រហ័ស ដូចអណ្តាតដឹងនូវរសសម្ល។

ចរន្តិ ពាលា ទុម្មេធា　　អមិត្តេនេវ អត្តនា
ករោន្តា បាបកំ កម្មំ　　យំ ហោតិ កដុកប្ផលំ ។

ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ តែងធ្វើកម្មលាមកដែលជាអំពើមានផលក្តៅក្រហាយ។

ន តំ កម្មំ កតំ សាធុ　　យំ កត្វា អនុតប្បតិ
យស្ស អស្សុមុខោ រោទំ　　វិបាកំ បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមុខប្រឡាក់ដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថាជាកម្មមិនល្អឡើយ។

តញ្ច កម្មំ កតំ សាធុ　　យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ　　វិបាកំ បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ឬដល់នូវសេចក្តីពេញចិត្តមានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថាជាកម្មល្អ។

មធុវា មញ្ញតិ ពាលោ　　យាវ បាបំ ន បច្ចតិ

យថា ច បច្ចតិ ចាបំ ពាលោ ទុក្ខំ និគច្ឆតិ ។

បាបមិនទាន់ឲ្យផលត្រឹមណា ជនពាល តែងសំគាល់នូវបាបនោះថាដូចទឹកឃ្មុំ លុះតែកាលណាបាបឲ្យផល ជនពាលទើបប្រទះនូវសេចក្តីទុក្ខ ក្នុងកាលនោះ។

មាសេ មាសេ កុសគ្គេន ពាលោ ភុញ្ជេថ ភោជនំ
ន សោ សង្ខាតធម្មានំ កលំ អគ្ឃតិ សោឡសឹ ។

ជនពាលទុកជាបរិភោគភោជនដោយចុងស្បូវរាល់ ៗ ខែ ជនពាលនោះក៏មិនដល់មួយចំណិតនៃចំណែកទី ១៦ ៗ លើករបស់បុគ្គលទាំងឡាយ ដែលមានធម៌បានដឹង ឬបានពិចារណាហើយឡើយ។

ន ហិ បាបំ កតំ កម្មំ សជ្ជុ ខីរំវ មុច្ចតិ
ឌហន្តំ ពាលមន្វេតិ ភស្មាឆន្នោវ បាវកោ ។

កម្មលាមកដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះក៏មាន ដូចទឹកដោះស្រស់ ដែលមិនទាន់ប្រែក្លាយដូច្នោះ បាបកម្មនោះតាមដុតបុគ្គលពាលដូចរងើកភ្លើងដែលបិទបាំងទុកដោយផេះដូច្នោះ។

យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ
ហន្តិ ពាលស្ស សុក្កំសំ មុទ្ធំ អស្ស វិបាតយំ ។

ការចេះដឹង កើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ រមែងញុំាងបញ្ញាឲ្យធ្លាក់ចុះ បំផ្លេចបំផ្លាញចំណែកធម៌សគឺកុសលរបស់បុគ្គលពាលនោះ។

អសន្តំ ភាវនមិច្ឆេយ្យ បុរេក្ខារញ្ច ភិក្ខុសុ
អាវាសេសុ ច ឥស្សរិយំ បូជា បរកុលេសុ ច ។

ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមានក្នុងខ្លួនផងនូវការធ្វើក្នុងខាងមុខគឺជាប្រមុខក្នុងពួកភិក្ខុផង នូវភាពជាឥស្សរៈ ក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយ ក្នុងត្រកូលនៃជនទាំងឡាយដទៃផង។

មមេវ កត មញ្ញន្តុ គិហីបព្ពជិតា ឧភោ
មមេវាតិវសា អស្សុ កិច្ចាកិច្ចេសុ កិស្មិចិ

### ឥតិ ពាលស្ស សង្កប្បោ ឥច្ឆា មានោ ច វឌ្ឍតិ ។

ភិក្ខុពាល តែងមានសេចក្តីត្រិះរិះថា គ្រហស្ថនឹងបព្វជិត ទាំង ២ ពួក ចូរសំគាល់នូវកិច្ចដែលមនុស្សដទៃ ធ្វើហើយថាជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែងរបស់អញ ចូរមានក្នុងកិច្ចតូច ធំ ណាៗមួយ ឬស្យា នឹងមានះរមែងចំរើន។

### អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី
### ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ
### សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ ។

បដិបទា អាស្រ័យនូវលាភផ្សេង បដិបទាជាដំណើរទៅកាន់ព្រះនិព្វានផ្សេង ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធ ដឹងច្បាស់នូវហេតុនុះយ៉ាងនេះហើយ មិនគួរត្រេកអរ ចំពោះសក្ការៈឡើយ គប្បីញ៉ាំងវិវេកឲ្យបំរើដោយលំដាប់ ។

## ព័ត៌មានផ្សេងៗ សូមទាក់ទង:

| | |
|---|---|
| អាសយដ្ឋាន: | ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា<br>ភ្នំអដ្ឋវស្ស ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល |
| យូធូប: | ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា |
| ឬ | ព្រះធម្មវិបស្សនា សំ ប៊ុនធឿន កេតុធម្មោ |
| វើបសាយ: | BVDCC.org |
| អ៊ីម៉ែល: | chhenchhoun@gmail.com |
| ទំនាក់ទំនង: | **០៨៦ ៨៧ ៧៧ ៩៣/០៨៨ ៧៨៩ ៥ ៩៩៩** |

**សូមអរព្រះគុណ និងអរគុណ !**